ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៤
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ៣៩១
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌលេខ ៥០"ឃ"/៦២១
ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាបនាសាលសវនាការលេខ:ខ០២។

កាលបរិច្ឆេទបើកសវនាការនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ២ និង៣០នាទីរសៀល។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៣រសៀល។

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប
លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប
លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ៤៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប មានជនជាប់ចោទ៖

១.ឈ្មោះ [redacted]សិត ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted]ធា ឪពុកឈ្មោះ [redacted] ស្ទូ (ស) ម្តាយឈ្មោះ [redacted] ខន (រ) ជាទីតិជន។ (គេចខ្លួន)

២.ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]



Scanned with CamScanner

ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ហ៊ុង (រ) ម្តាយឈ្មោះ [redacted] រឿង (រ) ជានីតិជន។ (គេចខ្លួន)

៣.ឈ្មោះ [redacted] ដាវ៉ាន់ ហៅ វណ្ណី ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] វ៉ាត (រ) ម្តាយឈ្មោះ [redacted] សឿន ជានីតិជន។ (គេចខ្លួន)

ជាប់ចោទពីបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ** ឬពិការភាព ប្រព្រឹត្ត នៅភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២២៣** នៃក្រមព្រហ្មទណ្ឌ។

-**ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] លីយ៉ា ភេទប្រុស អាយុ២៧ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

-បានឃើញរបាយការណ៍សំយោគចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៧៦ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ។

-បានឃើញដីកាដំណោះស្រាយលេខ ២៤២៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៨៣២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## ឯអង្គហេតុកើតមានដូចតទៅ

កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៨យប់ មានកម្មវិធីហែរផ្កាភ្លើងទៅវត្តមុនធ្យាន ខណៈពេលហែរដល់ចំណុចផ្សារញ៉ែ ភូមិរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ក៏មានទំនាស់ពាក្យសម្តី និងផ្ទុះហិង្សាវាយគ្នាទៅវិញទៅមករវាងមនុស្សពីរក្រុម គឺម្ខាងជាក្រុមរបស់ឈ្មោះ [redacted] លីយ៉ា និងភាគីម្ខាងទៀត បានធ្វើឱ្យឈ្មោះ [redacted] ហ៊ីន សន្លប់ ឈ្មោះ យ៉ាន ជី របួសស្រាលត្រូវគេបញ្ជូនទៅព្យាបាលនៅមណ្ឌលសុខភាព។ ក្រោយហែរចប់ ស្រាប់តែឈ្មោះ [redacted] សិត កាន់កាំបិតខ្វែវកាប់ទៅលើឈ្មោះ [redacted] លីយ៉ា ហើយឈ្មោះ [redacted] ហ៊ីវ និងឈ្មោះ [redacted] ដាវ៉ាន់ វាយទៅលើឈ្មោះ [redacted] លីយ៉ា បន្ថែម បណ្តាលឱ្យរងរបួសដាច់ដៃស្តាំ ត្រឹមកដៃ និងរបួសខ្នងផ្នែកខាងក្រោយ។ ក្រោយមកឈ្មោះ [redacted] សិត និងឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ បានរត់គេចខ្លួនពីមូលដ្ឋានបាត់។

## នាពេលសវនាការ

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីយ៉ា បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ៧យប់ ខ្លួនបានដើរហែរក្បួនដល់ខាងជើងផ្សារញ៉ែ ឃុំដានរុន ហួសបន្តិចក៏មានរឿងឈ្លោះប្រកែកគ្នារវាងក្រុមខ្លួន និងក្រុមអ្នកភូមិដានរុន ពេលនោះគេគប់ដបស៊ាំងមកលើខ្លួនតែការគប់នោះ មិនត្រូវអ្នកណាម្នាក់នោះទេ។ ដោយឃើញថាហែរមកមានរឿងជាមួយពួកខ្លួនក៏នាំគ្នាត្រឡប់មកវត្តវិញ ដើរតាមផ្លូវមុខសាលារៀនឃុំដានរុនបានហួសបន្តិច ស្រាប់តែឃើញមនុស្ស ០២នាក់ ចេញពីក្រោ

យសាលារៀន មានកាន់ប៉ែល និងកាន់ខ្សែរ កាប់មកលើខ្លួនចំត្រង់ចង្កេះ ១ខ្សែរ ត្រូវខាងស្តាំ ១ខ្សែរ (បណ្តាលឱ្យដាច់ប្រអប់ដៃស្តាំ) ពេលនោះខ្លួនបានដួល វាបានកាប់ ១ខ្សែរទៀត ត្រូវក្បាល ហើយបក្សពួករបស់គេម្នាក់ទៀតបានមកវាយថែម ១ប៉ែល ខាងឆ្វេង ពេលនោះមិត្តភក្តិរបស់ខ្លួនរត់មក ហើយពួកជនបង្កក៏រត់បាត់។ ខ្លួនចាំបានតែភាគជនដៃដល់មានសក់រួញ កម្ពស់ប្រហែល ១.៥០ម៉ែត្រ សម្បុរសណ្តែកបាយ អាយុប្រហែល ៣៥ឆ្នាំ។ ជនល្មើសកាប់ខ្លួនពីក្រោយ កាប់ដាច់ប្រអប់ដៃស្តាំម្ខាង ដោយពួកវាមានគ្នា០៣នាក់ ឯគ្នាវាម្នាក់ទៀតកាប់ខ្លួន ហើយ០២នាក់ទៀតនៅចាំផ្លូវ។

- តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] រិទ្ធ បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ វេលា ម៉ោង ប្រហែល ៩ និង ២០នាទី ស្រាប់តែមានគេទូរស័ព្ទមកប្រាប់ខ្លួនថា កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] លីយ៉ា ត្រូវគេ កាប់នៅផ្សារញ៉ៅ ភូមិដានរុនខាងត្បូង បែកក្បាល និងដាច់ដៃ ដឹកដល់ពេទ្យរ៉េតហើយ ពេលលឺភ្លាមខ្លួនបានជិះម៉ូតូទៅមើលកូន ដោយសភាពរងរបួសធ្ងន់ពេក ក៏បញ្ជូនបន្តទៅគ្លីនិចពេទ្យរ៉េតនៅខេត្តទាំងយប់ ទើបដឹងខ្លួន។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted]សាវ៉ាន់ បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ២០យប់ ស្រាប់តែឃើញឈ្មោះ ភាវ ជា និងឈ្មោះ [redacted] ហ៊ីន ចូលមកឱ្យខ្លួនដេរស្លឹកត្រចៀក គាត់បានប្រាប់ថា ដោយសារត្រូវគេកាប់ តែខ្លួនពុំបានសួរនាំអ្វីទៀតនោះទេ។ ខ្លួនដេរទើបតែបាន ៣ថ្នេរ ស្រាប់តែមានគេដឹកអ្នករបួសម្នាក់ទៀត ដាច់ដៃ និងបែកក្បាលដាក់ចោលរួចទៅបាត់ ដោយសាររបួសធ្ងន់ពេក ខ្លួនក៏ប្រាប់ឈ្មោះ វ៉ាន់ ដែលកំពុងឈរក្បែរនោះ ក៏បានជួយដឹកទៅមន្ទីរពេទ្យតែម្តង បន្ទាប់មកមានម៉ូតូ០១គ្រឿង បានជិះដោយមិនស្គាល់អត្តសញ្ញាណ ០២នាក់ ប្រដាប់ដោយកាំបិត និងពូថៅ មកសួររកអ្នករបួសដាច់ដៃនោះ រួចក៏ចេញទៅវិញបាត់។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] រេងរ៉ៃ បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ ខ្លួនជិះ ម៉ូតូពីផ្ទះបំណងទៅហែរផ្កាភ្លើងនៅវត្តមុនធ្យាន ពេលជិះដល់មុខផ្ទះពេទ្យរ៉ៃ ឃើញមានមនុស្សអ៊ូអរបានចូលមើលឃើញបុរសម្នាក់ត្រូវគេកាប់ដាច់ដៃ ហើយពេទ្យរ៉ៃមិនហ៊ានមើល ក៏ប្រាប់ឱ្យដឹកទៅមន្ទីរពេទ្យស្រុក ដោយគ្មានអ្នកជួយ ខ្លួនបានដឹកជូនទៅមន្ទីរពេទ្យគ្លីនិកស៊ីងរិទ្ធីរ៉េត។ ពេលនោះក្រុមគ្រួសារជនរងគ្រោះក៏មកដល់ ខ្លួនក៏ចេញទៅវត្តមុនធ្យានវិញ។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ញ៉ី បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ ខ្លួនបានបើកតូបលក់ដូចសព្វដង ស្រាប់តែមានមនុស្សវាយគ្នាតាមផ្លូវ ហើយខ្លួនបានរត់ទៅយកដបសាំង ដែលខ្លួនដាក់ លក់ ពួកគេរត់ដេញគ្នាទៅទិសខាងជើងបាត់ខ្លួន ឃើញម៉ូតូ ០១គ្រឿង ដួលលើផ្លូវមុខរោងម៉ាស៊ីនស្រូវរបស់ ឈ្មោះ ខា អាទស្រី ពេលនោះឈ្មោះ [redacted] ម៉ុឌុះ បានរួសយកទុកនៅតូប ខ្លួនបានប្រាប់ឱ្យយកទៅទុកនៅតូបខ្លួន តែខ្លួនបានប្រាប់ឱ្យយកទៅទុកនៅប៉ុស្តិ៍នគរបាល។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ុន បានឆ្លើយថា៖ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ២០យប់ ខ្លួនបានដើរចេញពីផ្ទះដើម្បីទៅហែរភ្លើង នៅភូមិដានរុនខាងត្បូង ហើយក៏បានឃើញមនុស្សកំពុងវាយគ្នា ពេលនោះខ្លួនបានឃើញឈ្មោះ សិទ្ធ បានយកម្ចុកការពារទៅវាយម៉ូតូ ដែលដួល ពេលពួកគេចេញអស់ ខ្លួនក៏បានយកម៉ូតូទៅទុកនៅប៉ុស្តិ៍ មកដល់កែងផ្សារក៏ពួកវាថា ពួកគេជាម្ចាស់ម៉ូតូ ហើយសុំយកម៉ូតូវិញ ខ្លួនក៏បានឱ្យវិញ រួចខ្លួនក៏ត្រឡប់មកផ្ទះវិញ។

- **តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពីបានធ្វើការពិភាក្សាដេញដោលក្នុង ពេលសវនាការរួចមក ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី បញ្ជាក់ឱ្យឃើញថា មានជម្លោះគ្នារហូតមានការប្រវាយប្រតប់គ្នាដោយប្រើសម្ភារៈកាំបិតខ្វែង និងប៉ែល បានវាយទៅលើជនរងគ្រោះ បណ្តាលឱ្យដាច់ប្រអប់ដៃស្តាំ ក្រោយពេលប្រព្រឹត្តបទល្មើសរួចជនជាប់ចោទបានគេចខ្លួន ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែលនិងស្នើសុំសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- **លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា:** ក្នុងរឿងនេះ ក្រោយឆ្លងកាត់សវនាការ និងពិនិត្យមើលសំណុំរឿងមកឃើញថា កូនក្តីខ្លួនឈ្មោះ [redacted] សិត ឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ ត្រូវបានចោទប្រកាន់ក្រោមអង្គហេតុថា កាលពីខែតុលា ឆ្នាំ២០២១ ជនជាប់ចោទទាំងបីនាក់ បានប្រព្រឹត្តហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយការកាត់អវៈយវៈ ឬពិការ នៅភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកស្វាយទិគម ខេត្តសៀមរាប មកលើជនរងគ្រោះ ឈ្មោះ [redacted] លីយ៉ា បណ្តាលឱ្យរងរបួសដាច់ប្រអប់ដៃ។ តាមចម្លើយរបស់ជនរងគ្រោះ និងសាក្សី ខ្លួនកត់សម្គាល់ឃើញថា ពិតជាវាយតបគ្នាមែន ជនរងគ្រោះពិតជាមានរបួសពិតប្រាកដណាស់ មានសាក្សីពិតជាបានឃើញជនជាប់ចោទឈ្មោះ [redacted] សិត កាន់ខ្វែរ និងមានបក្សពួករួមប្រព្រឹត្តបទល្មើសនេះមែនតែបក្សពួកមានគ្នាច្រើនមិនបានបញ្ជាក់ថាចំមកលើជនជាប់ចោទឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់។ ចម្លើយទាំងនេះសុទ្ធតែជាចម្លើយតែម្ខាងតែប៉ុណ្ណោះ មួយវិញទៀតឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ អាចជាបក្សពួកដែលខស្យាហ៍ដើរលេងជាមួយគ្នា តែក៏មិនអាចថាជាជនដែលបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ខាងលើដែរ ម្យ៉ាងជនជាប់ចោទទាំងពីរជាអនីតិជនទៀត មិនមានការគិតវែងឆ្ងាយទើបសែបគប់ខុសបែបនេះ។ សរុបសេចក្តីមកក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សិត ឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ ខ្លួនសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ មុនធ្វើការសម្រេចសុំពិចារណា ទៅលើភស្តុតាងក្នុងរឿងនេះ និងសម្រេចតាមផ្លូវច្បាប់។

- ដើមបណ្តឹងរដ្ឋប្បវេណីបានសំណូមពរប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងប្តឹងសុំទាមទារសំណងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តសរុប ១០០,០០០០០០ (មួយរយលាន) រៀល។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយនិងអំណានចម្លើយរបស់សាក្សីបំភ្លឺ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តសៀមរាប
## យល់ឃើញថា

- កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៨យប់ មានកម្មវិធីហែរផ្កាភ្លើងទៅវត្តមុនធ្យាន ខណៈពេលហែរដល់ចំណុចផ្សារវ៉ៃញ៉ែ ភូមិរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ក៏មានទំនាស់ពាក្យ សម្តី និងផ្ទុះហិង្សាវាយគ្នាទៅវិញទៅមករវាងមនុស្សពីរក្រុម គឺម្ខាងជាក្រុមរបស់ឈ្មោះ [redacted] លីយ៉ា និងភាគីម្ខាងទៀត បានធ្វើឱ្យឈ្មោះ [redacted] ហ៊ុន សន្លប់ ឈ្មោះ [redacted] ជី របួសស្រាលត្រូវគេបញ្ជូនទៅព្យាបាលនៅមណ្ឌលសុខភាព។ ក្រោយហែរចប់ ស្រាប់តែឈ្មោះ [redacted] សិត កាន់កាំបិតខ្វែវកាប់ទៅលើឈ្មោះ [redacted] បីយ៉ា ហើយឈ្មោះ [redacted] ហ៊ីវ និងឈ្មោះ [redacted] ដាវ៉ាន់ វាយទៅលើឈ្មោះ [redacted] លីយ៉ា បន្ថែម បណ្តាលឱ្យរងរបួសដាច់ដៃស្តាំ ត្រឹមកដៃ និងរបួសខ្នងផ្នែកខាងក្រោយ។ ក្រោយមកឈ្មោះ [redacted] សិត និងឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ បានរត់គេចខ្លួនពីមូលដ្ឋានបាត់។

- ជនចាប់ចោទឈ្មោះ [redacted] សិត ភេទប្រុស អាយុ៣២ឆ្នាំ ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ដាវ៉ាន់ ហៅ វល្លិ៍ ភេទប្រុស អាយុ១៦ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួររបស់សាលាដំបូងខេត្តសៀមរាប បញ្ជូនទៅជំនុំជម្រះពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព ប្រព្រឹត្តនៅភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយសាក្សី មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ និងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងឯកសារនានាដែលមាននៅក្នុងសំណុំរឿង ដូចនេះអាចឱ្យតុលាការជឿបានថាជនជាប់ចោទពិតជាបានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះបណ្តាលឱ្យដាច់ប្រអប់ដៃម្ខាងប្រាកដមែន ក្នុងនោះជនជាប់ចោទមានបក្សពួករហូតដល់០៣នាក់ ហើយមានកាន់កាំបិតខ្វែវ និងមានចេតនាកាប់ទៅលើជនរងគ្រោះ។

- **សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការថា** ជនជាប់ចោទ និងជនរងគ្រោះ មានជម្លោះគ្នារហូតមានការប្រវាយប្រតប់គ្នាដោយប្រើសម្ភារៈកាំបិតខ្វែង និងប៉ែល បានវាយទៅលើជនរងគ្រោះបណ្តាលឱ្យដាច់ប្រអប់ដៃស្តាំ ក្រោយមក ជនជាប់ចោទប្រព្រឹត្តបទល្មើសរួចបានគេចខ្លួនបាត់ ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ គប្បីតុលាការសម្រេចតាមច្បាប់។

- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទថា ក្នុងរឿងនេះក្រោយឆ្លងកាត់សវនាការ និងពិនិត្យមើលសំណុំរឿងមកឃើញថា កូនក្តីខ្លួនឈ្មោះ [redacted]សិត ឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ ត្រូវបានចោទប្រកាន់ក្រោមអង្គហេតុថា កាលពីខែតុលា ឆ្នាំ២០២១ ជនជាប់ចោទទាំងបីនាក់ បានប្រព្រឹត្តហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយការកាត់អវៈយវៈ ឬពិការ នៅភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប មកលើជនរងគ្រោះ ឈ្មោះ វី លីយ៉ា បណ្តាលឱ្យរងរបួសដាច់ប្រអប់ដៃ។ តាមចម្លើយរបស់ជនរងគ្រោះ និងសាក្សី ខ្លួនកត់សម្គាល់ឃើញថា ពិតជាវាយតបគ្នាមែន ជនរងគ្រោះពិតជាមានរបួសពិតប្រាកដណាស់ មានសាក្សីពិតជាបានឃើញជនជាប់ចោទឈ្មោះ [redacted]សិត កាន់ខ្វែវ និងមានបក្សពួករួមប្រព្រឹត្តបទល្មើសនេះមែនតែបក្សពួកមានគ្នាច្រើនមិនបានបញ្ជាក់ថាចំមកលើជនជាប់ចោទឈ្មោះ [redacted] ហុង និងឈ្មោះ [redacted]ដាវ៉ាន់។ ចម្លើយទាំងនេះសុទ្ធតែជាចម្លើយតែម្ខាងតែប៉ុណ្ណោះ មួយវិញទៀតឈ្មោះ ហ៊ីង ហុង និងឈ្មោះ [redacted] ដាវ៉ាន់ អាចជាបក្សពួកដែលឧស្សាហ៍ដើរជាមួយគ្នា តែក៏មិនអាចថាជាជនដែលបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ខាងលើដែរ ម្យ៉ាងជនជាប់ចោទទាំងពីរជាអនីតិជនទៀត មិនមានការគិតវែងឆ្ងាយទើបសែបគប់ខុសបែបនេះ។ សរុបសេចក្តីមកក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សិត ឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ ខ្លួនសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ មុនធ្វើការសម្រេចសូមពិចារណាទៅលើភស្តុតាងក្នុងរឿងនេះ និងសម្រេចតាមផ្លូវច្បាប់។ គប្បីតុលាការលើកយកមកពិចារណាសម្រេចតាមច្បាប់។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់រូបរាង្គកាយអ្នកដទៃ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជាពិសេសខុសនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-ជនជាប់ចោទជាជនដែលអាចយល់ដឹងគ្រប់គ្រាន់ និងមានស្មារតីរឹងមាំអាចដឹងចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ដូច្នេះអាចទទួលការចោទប្រកាន់ និងទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សិត ភេទប្រុស អាយុ៣២ឆ្នាំ ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted]ដាវ៉ាន់ ភេទប្រុស អាយុ១៦ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព ប្រព្រឹត្តនៅភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៣ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] ហុង ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ[redacted] ដាវ៉ាន ភេទប្រុស អាយុ១៦ឆ្នាំ ជាអនីតិជន គប្បីទទួលបានស្ថានសម្រាលទោសស្របតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted]សិត ឈ្មោះ ហ៊ីង ហុង និងឈ្មោះ[redacted] ដាវ៉ាន់ ក្រោយពេលប្រព្រឹត្តបទល្មើសបានរត់គេចខ្លួន គប្បីតុលាការចេញដីកាចាប់ផ្តេកឃុំខ្លួនតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីយ៉ា ប្តឹងទាមទារថ្លៃព្យាបាលរបួស និងជំងឺចិត្ត ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល គប្បីតុលាការ ពិចារណាសម្រេចតាមស្ថានភាពជាក់ស្តែង។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសលើ ៖

ក.ឈ្មោះ [redacted] សិត ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៨ (ប្រាំបី)ឆ្នាំ។

ខ.ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៨(ប្រាំបី)ឆ្នាំ។

គ.ឈ្មោះ [redacted] ដាវ៉ាន់ ហៅ វល្លិ៍ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៨(ប្រាំបី)ឆ្នាំ។

ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព ប្រព្រឹត្តនៅភូមិដានរុនខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៣ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

២-ចេញដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួនលើឈ្មោះ [redacted] សិត ភេទប្រុស អាយុ៣២ឆ្នាំ , ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ដាវ៉ាន់ ភេទប្រុស អាយុ១៦ឆ្នាំ ផ្អែកតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យឈ្មោះ [redacted] សិត និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឱ្យឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] ដាវ៉ាន់ ត្រូវសងសំណងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីយ៉ា ។ ការទាមទារលើសពីនេះបដិសេធចោល។

- សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ។

"ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់"។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

សៀមរាប ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]